## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៖** ១១៦ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២១/៧៥៣ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ជា វ៉ាន់ដេត** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រធាន |
| ២. ឯកឧត្តម **អៀង ស៊ុនលី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម **សំរិទ្ធ ឌី** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. ឯកឧត្តម **ញឹម ខេមរា** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

| | | |
|---|---|---|
| ៥. ឯកឧត្តម **ជុន វ៉ាត** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| ៦. ឯកឧត្តម **ចោង ចិន្តា** | ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៧. ឯកឧត្តម **លីវ សុផាណារិទ្ធិ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៨. ឯកឧត្តម នាយឧត្តមសេនីយ៍ **ឆៃ ស៊ីណារិទ្ធ** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ៩. ឯកឧត្តម **ខ៉ាន់ ដានី** | អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១០. ឯកឧត្តម ឧត្តមសេនីយ៍ឯក **សូខន បញ្ញារិទ្ធិ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១១. លោកឧត្តមសេនីយ៍ទោ **ម៉ៅ គន្ធា** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១២. លោក **ចេង ខៀ** | អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| ១៣. លោក **ធូ នា** | អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក |
| ១៤. លោកស្រី **ឡូញ ឈាង** | អភិបាលរងនៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| ១៥. លោក **ង៉ោ ម៉េងជួន** | អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ១៦. លោក **ហួន វ៉ាន់និត** | អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| ១៧. លោក **លី សារ៉ារិទ្ធ** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ | សមាជិក |
| ១៨. លោក **ជា ថាវរិទ្ធ** | អភិបាលរងនៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| ១៩. លោក **លន់ សុភាព** | អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| ២០. លោក **ជាក់ ម៉េងហ៊ាង** | អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ២១. លោក **ប៉ែន លីណាត** | អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ | សមាជិក |
| ២២. លោក **ពាង ណារិទ្ធ** | អភិបាលរងនៃគណៈអភិបាលខេត្តត្បូងឃ្មុំ | សមាជិក |
| ២៣. លោក **សេង សីលា** | អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង | សមាជិក |
| ២៤. លោក **ឌុច គន្ធា** | អភិបាលរងនៃគណៈអភិបាលខេត្តព្រៃវែង | សមាជិក |
| ២៥. លោក **ណុប ដារ៉ា** | អភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល | សមាជិក |
| ២៦. លោក **ខាន់ សុខា** | អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| ២៧. លោក **អ៊ឹង ឆាយ** | អភិបាលរងនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ២៨. លោក **គង់ វិសាណៈ** | អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ២៩. លោក **សុខ សុទ្ធី** | អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង | សមាជិក។ |

**ប្រការ២ .-**

គណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- បង្ការ បង្ក្រាប និងត្រួតពិនិត្យលើការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែន ដើម្បីធានាអធិបតេយ្យភាព ប្រសិទ្ធភាព សុវត្ថិភាព និងគុណភាពនៃការផ្តល់សេវាទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំផែនការកែសម្រួលរាល់ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍អន្តរជាតិនៅតាមបណ្តោយព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវបង្វែរឱ្យមកឆ្លងកាត់ច្រកទ្វារអ៊ីនធឺណិតជាតិ
- ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និង/ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីស្រាវជ្រាវស៊ើបអង្កេត ទប់ស្កាត់ និងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់
- សម្របសម្រួលជាមួយបណ្តាប្រទេសជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជាលើការងារគ្រប់គ្រងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់សេវាទូរគមនាគមន៍អន្តរជាតិ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រមុខរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ .-**

គណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ មានលេខាធិការដ្ឋានមួយជាសេនាធិការ។

សមាសភាពជាក់ស្តែង តួនាទីនិងភារកិច្ចនៃលេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៤ .-**

អនុប្រធាន សមាជិក និងសមាសភាពលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង។ ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញសមាសភាពពាក់ព័ន្ធផ្សេងទៀតមកចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ៥ .-**

គណៈកម្មការអន្តរក្រសួងដើម្បីបង្ការនិងបង្ក្រាបការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងការប្រើប្រាស់សេវាទូរគមនាគមន៍ឆ្លងដែនខុសច្បាប់ មានសិទ្ធិប្រើត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការបំពេញតួនាទីនិងភារកិច្ចដូចមានចែងក្នុងសេចក្តីសម្រេចនេះ។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ